# គំរោងប្រាក់ជំនួយថ្លៃថ្នាំពេទ្យ (PBS)

## តើ PBS ជាអ្វី?

ប្រភេទជាច្រើននៃថ្នាំពេទ្យមានតម្លៃច្រើនជាងតម្លៃដែលលោកអ្នកចំណាយ – ដោយព្រោះថ្នាំខ្លះមានតម្លៃរាប់រយដុល្លារ។ តាមរយៈគំរោងប្រាក់ជំនួយថ្លៃថ្នាំពេទ្យ (Pharmaceutical Benefits Scheme - PBS) រដ្ឋាភិបាលអូស្ត្រាលីជួយចេញថ្លៃសំរាប់ថ្នាំពេទ្យតាមវេជ្ជបញ្ជាមួយចំនួនយ៉ាងធំទូលាយ។ គំរោងប្រាក់ជំនួយថ្លៃថ្នាំពេទ្យមាតុភូមិនិវត្តន៍ (Repatriation Pharmaceutical Benefits Scheme - RPBS) ផ្តល់លទ្ធភាពទទួលយក PBS និងថ្នាំពេទ្យបន្ថែមទៀត សំរាប់អតីតយុទ្ធជន មេម៉ាយ ឬពោះម៉ាយដោយសារសង្គ្រាម និងកូនក្នុងបន្ទុករបស់អ្នកទាំងនោះ។

## តើខ្ញុំមានសិទ្ធិទទួល PBS ឬទេ?

ពលរដ្ឋអូស្ត្រាលីទាំងអស់អាចទិញថ្នាំពេទ្យតាមតម្លៃថោកសមរម្យ តាមរយៈ PBS។

ថ្នាំពេទ្យ PBS ក៏មានផងដែរសំរាប់ភ្ញៀវមានសិទ្ធិទទួលមកពីប្រទេសអ៊ីតាលី នូវ៉េលហ្សេឡង់ សាធារណរដ្ឋអៀរឡង់ ហ្វាំងឡង់ ន័រវេ ម៉ាល់តា ហុល្លង់ ស៊ុយអែដ បែលជិម និងចក្រភពអង់គ្លេស។ ប្រទេសអូស្ត្រាលីមានកិច្ចព្រមព្រៀងថែទាំសុខភាពទៅវិញទៅមកជាមួយនឹងប្រទេសទាំងនេះ។

## តើខ្ញុំនឹងត្រូវបង់ប្រាក់ប៉ុន្មាន?

តម្លៃដែលលោកអ្នកចំណាយសំរាប់ថ្នាំពេទ្យ PBS ផ្អែកលើកម្រិតនៃសិទ្ធិទទួលរបស់លោកអ្នក។ ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2011 តទៅ ទៅតាមអត្រាទូទៅ ប្រាក់រួមចំណែកអ្នកជំងឺរបស់លោកអ្នកគឺមានចំនួនដល់ទៅ $34.20# សំរាប់ថ្នាំពេទ្យ PBS នីមួយៗ។ បើលោកអ្នកមានប័ណ្ណសម្បទានមានសុពលភាពមួយពី Centrelink ឬក្រសួងកិច្ចការអតីតយុទ្ធជន (Department of Veterans' Affairs - DVA) ការរួមចំណែកអ្នកជំងឺរបស់លោកអ្នកគឺនៅនឹងអត្រាសម្បទានចំនួន $5.60#។

បើលោកអ្នកមានប័ណ្ណពណ៌ស DVA សំរាប់ស្ថានភាពជាក់លាក់ទាំងឡាយ ហើយថ្នាំពេទ្យរបស់លោកអ្នកគឺសំរាប់ស្ថានភាពទាំងនោះ ប្រាក់រួមចំណែកអ្នកជំងឺរបស់លោកអ្នកនឹងមានចំនួន $5.60# បើពុំនោះសោតទេ លោកអ្នកនឹងត្រូវបង់តាមអត្រាទូទៅ។

## តើខ្ញុំត្រូវធ្វើអ្វីទៅ?

ដើម្បីឲ្យប្រាកដថា លោកអ្នកបង់ថ្លៃតាមចំនួនត្រឹមត្រូវសំរាប់ថ្នាំពេទ្យរបស់លោកអ្នក ពេលដែលលោកអ្នកទិញថ្នាំពេទ្យមានវេជ្ជបញ្ជា សូមបង្ហាញឱសថការីនូវ៖

- ប័ណ្ណ Medicare គ្រាសព្វថ្ងៃរបស់លោកអ្នក
- ប័ណ្ណសម្បទាន Centrelink ឬ DVA គ្រាសព្វថ្ងៃរបស់លោកអ្នក (បើលោកអ្នកមាន)
- សិទ្ធិទទួលសំណាញ់សុវត្ថិភាព PBS (PBS Safety Net) ឬប័ណ្ណសម្បទាន គ្រាសព្វថ្ងៃរបស់លោកអ្នក (បើលោកអ្នកមាន)។

## តើមានអ្វីកើតឡើង បើខ្ញុំគ្មានប័ណ្ណទាំងឡាយរបស់ខ្ញុំនៅជាប់ជាមួយខ្លួនខ្ញុំ?

ជាការសំខាន់ក្នុងការមានប័ណ្ណទាំងឡាយរបស់លោកអ្នកនៅជាមួយខ្លួនលោកអ្នក នៅពេលទៅទិញថ្នាំពេទ្យតាមវេជ្ជបញ្ជារបស់លោកអ្នក។ បើលោកអ្នកគ្មានប័ណ្ណ Medicare ប័ណ្ណសម្បទាន ឬប័ណ្ណ Safety Net របស់លោកអ្នកទេ លោកអ្នកប្រហែលជាត្រូវបង់តាមតម្លៃខ្ពស់សំរាប់ថ្នាំពេទ្យរបស់លោកអ្នក។ បើហេតុការណ៍នេះកើតមានឡើង លោកអ្នកគួរសុំឱសថការីឲ្យផ្តល់បង្កាន់ដៃផ្លូវការសំរាប់ទទួលប្រាក់ PBS មកវិញ ## (មិនមែនជាបង្កាន់ដៃធម្មតាទេ) ហើយបំពេញពាក្យទាមទារសុំប្រាក់មកវិញសំរាប់អ្នកជំងឺ PBS។ លោកអ្នកអាចទាញយកពាក្យបំពេញនេះពី **www.medicareaustralia.gov.au** ឬទៅយកពីការិយាល័យ Medicare ។

## តើខ្ញុំអាចសុំទិញថ្នាំពេទ្យម៉ាកផ្សេងដែលមានតម្លៃថោកជាងបានឬទេ?

លោកអ្នកអាចសុំវេជ្ជបណ្ឌិតឲ្យចេញវេជ្ជបញ្ជាទិញថ្នាំពេទ្យម៉ាកផ្សេងដែលមានតម្លៃថោកជាង ឬឱសថការីរបស់លោកអ្នកអាចផ្តល់ថ្នាំពេទ្យដែលមានតម្លៃថោកជាង ឬមានម៉ាកទូទៅ ទៅតាមវេជ្ជបញ្ជារបស់លោកអ្នក។

ថ្នាំពេទ្យម៉ាកដែលមានតម្លៃថោកជាង ឬម៉ាកទូទៅ ក៏មានគុណភាពល្អដូចគ្នាដែរ។ នៅក្នុងពេលដែលម៉ាកនោះអាចមានរូបរាងខុសគ្នា ក៏វាមានគ្រឿងផ្សំសកម្មដូចគ្នា ហើយបំពេញតាមស្តង់ដារខ្ពស់នៃគុណភាពសុវត្ថិភាព និងប្រសិទ្ធភាពរបស់រដ្ឋបាលទំនិញព្យាបាល (Therapeutic Goods Administration) ដែរ។

## សំណាញ់សុវត្ថិភាពនៃគំរោងប្រាក់ជំនួយថ្លៃថ្នាំពេទ្យ (PBS Safety Net)

### តើ PBS Safety Net ជាអ្វី?

បើលោកអ្នក ឬគ្រួសារលោកអ្នកត្រូវការថ្នាំពេទ្យយ៉ាងច្រើនក្នុងពេលមួយឆ្នាំ PBS Safety Net ជួយលោកអ្នកក្នុងការចំណាយសំរាប់ថ្លៃថ្នាំពេទ្យរបស់លោកអ្នក។ នៅពេលដែលថ្លៃចំណាយរបស់លោកអ្នក ឬគ្រួសារលោកអ្នកឈានដល់កម្រិតកំណត់ Safety Net ហើយ លោកអ្នកអាចដាក់ពាក្យសុំប័ណ្ណ PBS Safety Net — បន្ទាប់មក ថ្នាំពេទ្យ PBS របស់លោកអ្នកនឹងមានតម្លៃរឹតតែថោក ឬឥតគិតថ្លៃ # សំរាប់ពេលដែលនៅសល់ទាំងប៉ុន្មាននៃឆ្នាំប្រក្រតិទិននោះ។

### តើខ្ញុំត្រូវធ្វើអ្វីខ្លះ?

លោកអ្នកត្រូវរក្សាបញ្ជីថ្នាំពេទ្យ PBS របស់លោកអ្នកនៅលើក្រដាសកត់ត្រាថ្នាំពេទ្យតាមវេជ្ជបញ្ជា (Prescription Record Form- PRF) ដែលលោកអ្នកអាចយកបានពីឱសថស្ថានរបស់លោកអ្នក។ រៀងរាល់ពេលដែលលោកអ្នកទិញថ្នាំពេទ្យ PBS សូមប្រគល់ក្រដាសកត់ត្រានេះទៅឲ្យឱសថការី ដើម្បីកត់បញ្ចូលថ្នាំពេទ្យនោះទៅក្នុងក្រដាសកត់ត្រានេះ។ ឱសថការីរបស់លោកអ្នកប្រហែលជារក្សាទុកកំណត់ត្រានេះនៅក្នុងកុំព្យូទ័ររបស់ខ្លួនសំរាប់លោកអ្នក ប៉ុន្តែបើមិនអាចធ្វើបានទេ ឬបើលោកអ្នកទិញថ្នាំពេទ្យពីឱសថស្ថានផ្សេងៗគ្នា ការរក្សាទុកកំណត់ត្រារបស់លោកអ្នកផ្ទាល់គឺជាការប្រសើរបំផុត។

បើលោកអ្នកមានគ្រួសារ សូមសួរឱសថការីអំពីការគួបផ្សំចំនួនប្រាក់ដែលលោកអ្នកចំណាយ សំរាប់ធ្វើជាចំនួនសរុប Safety Net របស់គ្រួសារលោកអ្នក។

### តើនរណាខ្លះដែលអាចដាក់រួមបញ្ចូលក្នុងគ្រួសារ Safety Net មួយ?

គ្រួសារមានសិទ្ធិទទួល PBS Safety Net រួមមានលោកអ្នក និង៖

- ប្តី ឬប្រពន្ធ ឬគូកំណាន់ប្រៀបដូចជាប្តី ឬប្រពន្ធរបស់លោកអ្នក
- កូនមានអាយុតិចជាង 16 ឆ្នាំ ដែលស្ថិតក្នុងការថែទាំរបស់លោកអ្នកទាំងមូល ឬខ្លះៗ ឬក្នុងការថែទាំរបស់ប្តី ឬប្រពន្ធ ឬគូកំណាន់ប្រៀបដូចជាប្តី ឬប្រពន្ធរបស់លោកអ្នក
- សិស្សរៀនពេញពេលដែលមានអាយុតិចជាង 25 ឆ្នាំ ហើយដែលស្ថិតនៅក្នុងបន្ទុកពេញពេលនៃប្តី ឬប្រពន្ធ ឬគូកំណាន់ប្រៀបដូចជាប្តី ឬប្រពន្ធរបស់លោកអ្នក។

### តើកម្រិតកំណត់ Safety Net នៅគ្រាសព្វថ្ងៃមានចំនួនប៉ុន្មាន?

ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ 2011 តទៅ កម្រិតកំណត់អ្នកជំងឺទូទៅគឺ $1317.20 ហើយសំរាប់អ្នកមានប័ណ្ណសម្បទានគឺ $336.00 ។

### តើមានអ្វីកើតឡើង នៅពេលដែលខ្ញុំឈានដល់កម្រិតកំណត់ PBS Safety Net?

នៅពេលដែលលោកអ្នកហៀបនឹងឈានដល់កម្រិតកំណត់ Safety Net សូមសាកសួរឱសថការីរបស់លោកអ្នកអំពីរបៀបទទួលប័ណ្ណ Safety Net ។ នៅពេលដែលឱសថការីបានចេញឲ្យលោកអ្នកនូវប័ណ្ណ Safety Net សំរាប់ថ្នាំពេទ្យ PBS មួយហើយ ប្រាក់រួមចំណែករបស់អ្នកជំងឺ Safety Net របស់លោកអ្នកសំរាប់ពេលដែលនៅសេសសល់ទាំង

ប៉ុន្មាននៃឆ្នាំប្រក្រតិទិននឹងមានចំនួន៖

- $5.60# បើលោកអ្នកជាអ្នកជំងឺទូទៅ

ឬ

- ឥតគិតថ្លៃទេ# បើលោកអ្នកមានប័ណ្ណសម្បទានមួយ។

### តើមានអ្វីកើតឡើង បើខ្ញុំបានទទួលវេជ្ជបញ្ជាដែលគ្មាន PBS?

វេជ្ជបណ្ឌិតរបស់លោកអ្នកប្រហែលជាចេញវេជ្ជបញ្ជាឲ្យប្រើថ្នាំពេទ្យមួយ ដែលគ្មាននៅក្នុងបញ្ជីសំរាប់ PBS ឬគ្មានថ្នាំពេទ្យក្នុងបញ្ជី PBS សំរាប់ស្ថានភាពរបស់លោកអ្នក– ជួនកាលត្រូវគេហៅថា "វេជ្ជបញ្ជាឯកជន"។ វេជ្ជបណ្ឌិតរបស់លោកអ្នកនឹងប្រាប់ឲ្យដឹងអំពីហេតុការណ៍នេះនៅក្នុងវេជ្ជបញ្ជារបស់លោកអ្នក ហើយលោកអ្នកនឹងត្រូវបង់ថ្លៃថ្នាំពេទ្យពេញលេញនៅឯឱសថស្ថាន។ តម្លៃនៃថ្នាំពេទ្យតាមវេជ្ជបញ្ជាដែលគ្មាន PBS មិនរាប់បញ្ចូលទៅក្នុងកម្រិតកំណត់ PBS Safety Net របស់លោកអ្នកឡើយ។

### ការផ្គត់ផ្គង់ថ្នាំពេទ្យមុនពេលកំណត់ នៅក្រោមបទបញ្ញត្តិ Safety Net 20 ថ្ងៃ

ដើម្បីរក្សា PBS ឲ្យមានតម្លៃថោកសមរម្យសំរាប់ជនរាល់រូប លោកអ្នកមិនគួរទិញថ្នាំពេទ្យតាមវេជ្ជបញ្ជា PBS នៅមុនពេលដែលលោកអ្នកត្រូវការវាឡើយ។ នៅក្រោមបទបញ្ញត្តិ Safety Net 20 ថ្ងៃ ការផ្គត់ផ្គង់ថ្នាំពេទ្យសាជាថ្មីនៅមុនពេលកំណត់ គឺជាការផ្គត់ផ្គង់ដែលធ្វើឡើងក្នុងរង្វង់ពេល 20 ថ្ងៃ ក្រោយពីការផ្គត់ផ្គង់កាលគ្រាមុននៃថ្នាំពេទ្យដដែលនោះ។

បើលោកអ្នកត្រូវការថ្នាំពេទ្យសាជាថ្មីមុនពេលកំណត់ បទបញ្ញត្តិ Safety Net 20 ថ្ងៃមានន័យថា សំរាប់ថ្នាំពេទ្យ PBS ខ្លះ ការផ្គត់ផ្គង់ថ្នាំពេទ្យនេះនឹងមិនរាប់បញ្ចូលទៅក្នុងកម្រិតកំណត់ Safety Net ឡើយ។ បើលោកអ្នកបានឈានដល់កម្រិតកំណត់ Safety Net របស់លោកអ្នករួចហើយនោះ លោកអ្នកនឹងត្រូវបង់ប្រាក់រួមចំណែក PBS ជាធម្មតារបស់លោកអ្នក ជាជាងការបង់ថ្លៃតាមចំនួន Safety Net ដែលកាត់បន្ថយ។

### ប្រាក់រួមចំណែកអ្នកជំងឺ PBS ឆ្នាំ 2011

| | **អ្នកជំងឺទូទៅ** | **អ្នកមានប័ណ្ណសម្បទាន** |
|---|---|---|
| **ប្រាក់រួមចំណែកអ្នកជំងឺ** | រហូតដល់ $34.20† | $5.60† |
| **កម្រិតកំណត់ Safety Net** | $1317.20 | $336.00 |
| **ប្រាក់រួមចំណែកអ្នកជំងឺ Safety Net** | $5.60† | ឥតគិតថ្លៃ† |

† បើលោកអ្នកជ្រើសយកម៉ាកថ្នាំពេទ្យដែលមានតម្លៃថ្លៃជាង ឬវេជ្ជបណ្ឌិតរបស់លោកអ្នកចេញវេជ្ជបញ្ជាថ្នាំពេទ្យដែលមានតម្លៃថ្លៃ លោកអ្នកអាចត្រូវបង់ប្រាក់បន្ថែម – ចំនួនបន្ថែមដែលលោកអ្នកបង់ មិនរាប់បញ្ចូលទៅក្នុងកម្រិតកំណត់ PBS Safety Net របស់លោកអ្នកឡើយ។

## បញ្ជីផ្ទៀងផ្ទាត់ដោយសង្ខេប

- យកប័ណ្ណ Medicare របស់លោកអ្នក ព្រមជាមួយប័ណ្ណសម្បទាន DVA ឬ Centrelink និងប័ណ្ណ Safety Net របស់លោកអ្នក បើលោកអ្នកមានប័ណ្ណទាំងនេះ នៅពេលលោកអ្នកទៅទិញថ្នាំពេទ្យតាមវេជ្ជបញ្ជា PBS របស់លោកអ្នក។
- សួរវេជ្ជបណ្ឌិត ឬឱសថការីរបស់លោកអ្នក ថាតើមានថ្នាំពេទ្យថោកជាងថ្នាំពេទ្យដែលចេញឲ្យប្រើដោយវេជ្ជបញ្ជាឬទេ។
- និយាយទៅកាន់ឱសថការីរបស់លោកអ្នកអំពី PBS Safety Net – រក្សាទុក PRF ឬសុំឲ្យឱសថការីរបស់លោកអ្នករក្សាកំណត់ត្រាសំរាប់លោកអ្នក និងគ្រួសារលោកអ្នក។

- នៅពេលលោកអ្នកហៀបនឹងឈានដល់កម្រិតកំណត់ Safety Net សូមសួរឱសថការីរបស់លោកអ្នកអំពីរបៀបទទួលប័ណ្ណ Safety Net មួយ។

## ចំពោះព័ត៌មានបន្ថែម

| | |
|---|---|
| វ៉ិបសាយ | **www.medicareaustralia.gov.au** |
| អ៊ីមែល | **pbs@medicareaustralia.gov.au** |
| ទូរស័ព្ទ | **1800 020 613**** |
| TTY | **1800 552 152**** (ចំពោះអ្នកមានពិការភាពខាងស្តាប់ និងនិយាយ) |
| TIS | **131 450*** (កិច្ចបំរើបកប្រែភាសា) |

# បើលោកអ្នកជ្រើសយកម៉ាកថ្នាំពេទ្យដែលមានតម្លៃថ្លៃជាង ឬវេជ្ជបណ្ឌិតរបស់លោកអ្នកចេញវេជ្ជបញ្ជាថ្នាំពេទ្យដែលមានតម្លៃថ្លៃ លោកអ្នកអាចត្រូវបង់ប្រាក់បន្ថែម។

## ប្រាក់ជំនួយដែលលោកអ្នកទទួលមកវិញ ប្រហែលជាមិនគ្រប់ចំនួនពេញលេញដែលលោកអ្នកបានចំណាយសំរាប់ថ្នាំពេទ្យរបស់លោកអ្នកឡើយ។

*គិតថ្លៃទូរស័ព្ទ

**គិតថ្លៃទូរស័ព្ទចេញពីទូរស័ព្ទចល័ត និងទូរស័ព្ទដែលត្រូវបង់ថ្លៃសំរាប់ប្រើប៉ុណ្ណោះ។

1577_12b.20.01.11